ភ្នំពេញ, ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៤

# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា
# នៃព្រះរាជាណាចក្រកម្ពុជា

ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា និងអ្នកជំនាញឯករាជ្យ យល់ឃើញថា កិច្ចព្រមព្រៀងដំណោះស្រាយនយោបាយ កាលពីថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៤ រវាងគណបក្សប្រជាជកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានផ្តល់គោលការណ៍ជាមូលដ្ឋានមួយចំនួន ដើម្បីនាធាឲ្យដំណើររដ្ឋសភាមានប្រសិទ្ធិភាព និងតម្លាភាព ស្របតាមគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស និងរបបសភានិយមនៅកម្ពុជា។

កិច្ចព្រមព្រៀងដំណោះស្រាយនយោបាយនេះបានបញ្ជាក់ច្បាស់ថាត្រូវ «សិក្សា និងធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា» ដើម្បីធានា ១)ក្នុងការរៀបចំឲ្យមានការបែងចែកអំណាចដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ ដើម្បីឲ្យស្ថាប័នរដ្ឋសភាអាចបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវ និងកាន់តែមានប្រសិទ្ធិភាព ២)ការលើកកម្ពស់តួនាទី និងសិទ្ធិអំណាចរបស់គណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និង ៣) ការរៀបចំបែងចែកសិទ្ធិ និងអំណាចដឹកនាំស្ថាប័នរដ្ឋសភា ដោយបែងចែកតួនាទីដឹកនាំនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា តាមរូបមន្ត ០៧ ទល់ ០៦ ដែលគណបក្សដឹកនាំរាជរដ្ឋាភិបាលមានសមាសភាព០៧រូប និងគណបក្សមិនចូលរួមក្នុងរាជរដ្ឋាភិបាល ដែលមានអាសនៈក្នុងសភា មានសមាសភាព០៦រូប នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍។ គណបក្សដឹកនាំរាជរដ្ឋាភិបាល និងគណបក្សមិនចូលរួមក្នុងរាជរដ្ឋាភិបាលដែលមានអាសនៈក្នុងរដ្ឋសភាមានតួនាទីដឹកនាំគណៈកម្មការជំនាញចំនួន០៥ស្មើគ្នា។

ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា និងអ្នកជំនាញឯករាជ្យ យល់ឃើញថា កិច្ចព្រមព្រៀងដំណាក់កាលទី០១ ស្តីពីការចរចាធ្វើសេចក្តីព្រាងវិសោធកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៤ របស់ក្រុមការងារនៃគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិ មិនទាន់បានអនុវត្តចំណុចសំខាន់ៗនៃកិច្ចព្រម ព្រៀងថ្ងៃទី២២ កក្កដា ២០១៤ ប៉ុន្តែក្រុមការងារនៃគណបក្សទាំងពីរ បានសន្យាថា និងបន្តការពិភាក្សានៅតំណាក់ទីពីរ។

ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា និងអ្នកជំនាញឯករាជ្យ សូមផ្តល់នូវអនុសាសន៍សំខាន់ៗបន្ថែមក្នុងការធ្វើវិសោធនកម្មកែប្រែ ឬការបន្ថែមខ្លឹមសារមាត្រាច្បាប់រដ្ឋធម្មនុញ្ញ និងប្រការបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងមាត្រា១២០ថ្មីនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដូចខាងក្រោម៖

- រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង«ថ្មី» ដោយមតិពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីមិនមានបទបញ្ជាផ្ទៃក្នុងថ្មី បទបញ្ជាផ្ទៃក្នុងនៃអាណត្តិចុងក្រោយត្រូវចូលជាធរមាន។ (មាត្រា៨២ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ ៨២ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ត្រូវចែងអំពីការបែងចែកអំណាច ដឹកនាំរដ្ឋសភាក្នុងចំណោមគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមានសមាសភាពបុរស និងស្ត្រី ដូចរូបមន្តកិច្ចព្រមព្រៀងដំណោះស្រាយនយោបាយថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។ (ប្រការ ០២ថ្មី (ពីរ) និង ១០ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- គណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការជំនាញនីមួយៗ នៃរដ្ឋសភាត្រូវកំណត់ពេល ០១ (មួយ) ថ្ងៃ ក្នុង ០១ (មួយ) សប្តាហ៍ ដើម្បីធ្វើសវនាការសាធារណៈ ជជែកដេញដោល ដោយកោះហៅជនពាក់ព័ន្ធមកបំភ្លឺលើសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ និង ការអនុវត្តច្បាប់ជាធរមាន។ ទោះបីជាយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ។ គណៈកម្មាធិការអចិន្ត្រៃយ៍មានអំណាចទទួលពិនិត្យបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។ (ប្រការថ្មីបន្ថែមក្នុងជំពូក៣ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- កំណត់ហេតុទាំងអស់ និងឯកសារដទៃទៀតរបស់រដ្ឋសភា ត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋាន និង ជាសាធារណៈ លើកលែងតែជាកំណត់ហេតុ និងឯកសារទាំងឡាយណាដែលសំរេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍ថា អាចប៉ះពាល់ដល់សន្តិសុខជាតិ។ (ប្រការ១៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)។ អគ្គលេខាធិការដ្ឋានត្រូវរៀបចំឲ្យមានបទបញ្ជារដ្ឋបាល ដើម្បីធានាសិទ្ធិប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន និងចូលរួមក្នុងព្រឹត្តិការណ៍សាធារណៈរបស់រដ្ឋសភា។( ប្រការថ្មី បញ្ចូលទៅក្នុងជំពូកទី ៤)។
- គណៈកម្មការជំនាញនៃរដ្ឋសភា ត្រូវកោះហៅអ្នកព្រាងច្បាប់ និងអ្នកស្នើច្បាប់មកសាកសួរអំពីសេចក្តីពង្រាង និងសេចក្តីស្នើរច្បាប់ ក្នុងសវនាការសធារណៈ។ អ្នកតែងព្រាងច្បាប់ ឬអ្នកតែងសេចក្តីស្នើច្បាប់ មានសិទ្ធិចូលរាយការណ៍ជម្រាបគណៈកម្មការដែលពិនិត្យសេចក្តីស្នើនោះ។ (ប្រការ២៣ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)

- ចម្លើយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រី ត្រូវធ្វើឡើងក្នុងរយៈពេលដប់ប្រាំថ្ងៃ បន្ទាប់ពីទទួលបានសំណួរ។ ចំពោះចម្លើយផ្ទាល់មាត់តំណាងរាស្ត្រដាក់សំណួរ និងរាជរដ្ឋាភិបាលមានសិទ្ធិទទួលបានពេលវេលាស្មើគ្នាក្នុងការជជែកដេញដោល។ ចំពោះចម្លើយជាលាយលក្ខណ៍អក្សរ តំណាងរាស្ត្រដាក់សំណួរមានសិទ្ធិឆ្លើយតបក្នុងរដ្ឋសភាក្នុងរយៈពេលស្មើគ្នានឹងការអានចម្លើយជាលាយលក្ខណ៍អក្សររបស់រាជរដ្ឋាភិបាល។ (ប្រការ៣២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបយ៉ាងតិច ទើបរដ្ឋសភាលើកយកមកពិភាក្សាបាន។ ប្រសិនបើមានញត្តិបន្ទោសសមាជិកគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាលពីរដង រដ្ឋសភាត្រូវបើកប្រជុំពេញអង្គពិភាក្សា និងអនុម័តជាសាធារណៈក្នុងការទម្លាកមាជិកសមាជិកគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាល។ (ប្រការ៣៥ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)
- គណបក្សដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាលនិងមានអាសនៈច្រើនជាងនៅក្នុងរដ្ឋសភា ត្រូវបានទទួលស្គាល់ ហើយមានសិទ្ធិបង្កើតអ្នកនាំពាក្យក្នុងការត្រួតពិនិត្យការងាររបស់រាជរដ្ឋាភិបាល ហើយ អាចស្នើសុំឲ្យមានកិច្ចពិភាក្សាតទល់លើគោលនយោបាយរបស់រដ្ឋាភិបាល និង មានសិទ្ធិឆ្លើយតប ដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរទៅនឹងចម្លើយរបស់រាជរដ្ឋាភិបាលទៅនឹងសំណួររបស់តំណាងរាស្ត្រ។ (ប្រការថ្មី បញ្ចូលទៅក្នុងជំពូកទី ៩)
- សមាជិករដ្ឋសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ដោយសារសាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា ហើយបញ្ជាក់ពីមូលហេតុ និងផ្សព្វផ្សាយជាសាធារណៈ។ សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ដែលមានការសម្រេចជាលាយលក្ខណ៍អក្សរ តែមិនមែនមូលហេតុដោយសារការបញ្ចេញមតិខុសឆ្គង។ (មាត្រា ១២០ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ)
- យ៉ាងយូរបី(០៣)ថ្ងៃក្រោយពេលការប្រកាសលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាស្ថាពរ គណៈកម្មាធិការជាតិសម្រាប់ការបោះឆ្នោត ត្រូវរៀបចំបញ្ជីសមាជិកតំណាងរាស្ត្រដែលមានយ៉ាងតិច១២០រូបថ្វាយព្រះមហាក្សត្រ។ (មាត្រាថ្មី នៃជំពូកអំពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៃរដ្ឋធម្មនុញ្ញ)
- គណៈបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភាតិចជាងដប់ មានសិទ្ធិបង្កើតក្រុមរបស់ខ្លួនចំនួនមួយ(០១) ក្រុម។ (ប្រការ៤៨ថ្មី (ពីរ) បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា)

ក្រុមអង្គការសង្គមស៊ីវិល និងអ្នកជំនាញឯករាជ្យ បានរៀបចំសេចក្តីស្នើវិសោនកម្មរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងមាត្រា១២០ថ្មី នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដូចដែលមានភ្ជាប់ជាមួយសេចក្តីថ្លែងការណ៍នេះ។ ក្រុមអង្គការសង្គមស៊ីវិល និងអ្នកជំនាញឯករាជ្យត្រៀមរួចជាស្រេចក្នុងការចូលរួមបកស្រាយ សេចក្តីស្នើវិសោធនកម្មទាំងនេះ ទៅក្រុមការងារគណបក្សនយោបាយទាំងពីរ ឬក្រុមសមាជិកតំណាងរាស្ត្រ ឬក្រុមបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ ប្រសិនបើគណបក្សទាំងពីរផ្តល់ឱកាសឲ្យក្រុមអង្គការសង្គមស៊ីវិល និងអ្នកឯករាជ្យ។

**<u>ទំនាក់ទំនងព័ត៌មានបន្ថែម៖</u>**

| | | |
|---|---|---|
| • លោកបណ្ឌិត កែមឡី | អ្នកស្រាវជ្រាវសង្គមឯករាជ្យ | ០១២ ៧៨ ៧០ ៨៤ |
| • លោក អ៊ូ វីរៈ | ប្រធានក្រុមប្រឹក្សាភិបាល CCHR | ០១២ ៤០ ៤០ ៥១ |
| • លោក នី ចរិយា | ប្រធានផ្នែកស៊ើបអង្កេតADHOC | ០១១ ២៧ ៤៩ ៥៩ |
| • លោក គល់ បញ្ញា | នាយកប្រតិបត្តិអង្គការខុមហ្វ្រែល | ០១២ ៩៤ ២០ ១៧ |
| • លោកស្រី រស់ សុភាព | នាយិកាអង្គការ GADC | ០១២ ៦២ ៧៨ ៥៧ |

**<u>អង្គការគាំទ្រ៖</u>**

1. សមាគមអាដហុក ADHOC
2. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum)
3. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
4. អង្គការ ខុមហ្វ្រែល (COMFREL)
5. វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ(API)
6. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
7. អង្គការ GADC
8. អង្គការ និកហ្វិច
9. អគ្គលេខាធិការដ្ឋាន CHRAC
10. មជ្ឈមណ្ឌល PDP-Center
11. ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC)
12. អង្គការ KYSD
13. សម្ព័ន្ធ CISA

# សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា
# នៃព្រះរាជាណាចក្រកម្ពុជា
# រដ្ឋធម្មនុញ្ញ និងមាត្រាច្បាប់មួយចំនួនដែលពាក់ព័ន្ធ

បទបញ្ញាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា («បទបញ្ញាផ្ទៃក្នុង») ដែលមាន៨៣ មាត្រា និងចែកចេញជា១៧ជំពូក ត្រូវបានត្រួតពិនិត្យឡើងវិញ ឆ្លើយតបទៅនឹងកិច្ចព្រមព្រៀងដំណោះស្រាយនយោបាយនៃគណៈកម្មការចំរុះគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ និងគោលការណ៍គ្រឹះនៃវិធានសភាប្រជាធិបតេយ្យនៅកម្រិតអន្តរជាតិ។ គោលការណ៍ដែលត្រូវបានលើកយកមកត្រួតពិនិត្យនៅទីនេះរួមមាន៖ ១)ការផ្តល់អំណាចគ្រប់គ្រងឲ្យមតិភាគច្រើន៖ គោលការណ៍នេះស្របតាមលទ្ធិប្រជាធិបតេយ្យដែលតម្រូវឲ្យមតិភាគច្រើនមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចនានាប៉ុន្តែធានាឲ្យមាន។២) ការការពារសិទ្ធិចូលរួម និងបញ្ចេញមតិយោបល់របស់មតិភាគតិច។ ៣)សិទ្ធិអំណាចរបស់ចគណបក្សមានអាសនៈ ក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរដ្ឋាភិបាល។ ៤) តម្លាភាព និងការទទួលខុសត្រូវ ចំពោះមុខប្រជាម្ចាស់ឆ្នោត និង ៥)ការត្រួតពិនិត្យ និងតុល្យភាព។

គោលការណ៍នេះតម្រូវឲ្យអំណាចនីតិបញ្ញត្តិ និង អំណាចនីតិប្រតិបត្តិមានសិទ្ធិអំណាចត្រួតពិនិត្យលើគ្នាទៅវិញទៅមកក្នុងគោលបំណងធានាមិនឲ្យមានអំណាចហួសហេតុពីសំណាក់អំណាចណាមួយ។ ដោយហេតុថា វិធានសភាត្រូវបានបង្កើតឡើងក្នុងគោលបំណង ជាពិសេសធានាឲ្យមានភាពយុត្តិធម៌ និងសមភាពរវាងគណបក្សនយោបាយដែលទទួលបានសម្លេងឆ្នោតច្រើន (គណបក្សនយោបាយដឹកនាំរដ្ឋាភិបាល) និងគណបក្សនយោបាយដែលទទួលបានសម្លេងឆ្នោតតិច (គណបក្សនយោបាយនៅក្រៅរដ្ឋាភិបាល ដែលមានអាសនៈក្នុងរដ្ឋសភា) នៅក្នុងកិច្ចដំណើរការរដ្ឋសភា។ សំណើសុំធ្វើវិសោធនកម្មបទបញ្ញាផ្ទៃក្នុងនេះ («សេចក្តីស្នើវិសោធនកម្ម») ផ្តោតជាសំខាន់តែទៅលើបទបញ្ញត្តិនៃបទបញ្ញាផ្ទៃក្នុងណាដែលរកទៅឃើញថា មិនបានធានា ការពារតួនាទីសិទ្ធិអំណាចដល់សមាជិកសភានៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និងខ្វះតម្លាភាពនៃការចូលរួម។

## ជំពូកទី ១៖ អំពីការិយាល័យបណ្តោះអាសន្ន និងភារកិច្ច

ប្រការ២ ថ្មី (ពីរ) ចែងអំពី ការបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានរដ្ឋសភាដាច់ដោយឡែកពីគ្នាដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ប៉ុន្តែក្នុងករណីដែលស្ថានភាពនយោបាយ តម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ប្រធាន អនុប្រធាននៃរដ្ឋសភាដែលត្រូវបានបោះឆ្នោតជាកញ្ចប់ និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលនៅដើមនីតិកាលនីមួយៗដោយវិធីលើកដៃ និងដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។

ការបោះឆ្នោតដាច់ដោយឡែកជ្រើសរើសប្រធាន និងអនុប្រធានរដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ផ្តល់លទ្ធភាពឲ្យគណបក្សនយោបាយ ដែលដឹកនាំរាជរដ្ឋាភិបាលអាចរៀបចំ និងដំណើរការរដ្ឋសភាដោយឯកឯង ដោយគ្មានការចូលរួមពីសំណាក់គណបក្សនយោបាយដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល។ គោលការណ៍មិនបំពេញស្មារតីលទ្ធិប្រជាធិបតេយ្យដែលតម្រូវឲ្យមានការចូលរួមពីគ្រប់សំណាក់គណបក្សនយោបាយទាំងអស់(1) ដែលទទួលបានសម្លេងឆ្នោតពីប្រជាពលរដ្ឋទោះបីតិចក្តី ច្រើនក្តី ដើម្បីជាតំណាងឲ្យសម្លេងរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងរដ្ឋសភា។ ជាងនេះទៅទៀត យោងតាមបទបញ្ញត្តិ មិនមានចែងអំពីគោលការណ៍បែងចែកអំណាច ដែលតម្រូវឲ្យគណបក្សនយោ

---

(1) *សូមមើល* មាត្រា ១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

បាយនីមួយៗទទួលបានសមាមាត្រតំណែងប្រធាន ឬអនុប្រធានរដ្ឋសភា ឬការដឹកនាំគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការជំនាញផ្សេងៗរបស់រដ្ឋសភា ទៅតាមអាសនៈដែលខ្លួនទទួលបានឡើយ។ ការធ្វើដូច្នេះ គឺផ្តល់លទ្ធភាពឲ្យគណបក្សនយោបាយ ដែលទទួលបានសម្លេងឆ្នោតច្រើនកាន់កាប់ផ្តាច់មុខនូវមុខដំណែងដឹកនាំរបស់រដ្ឋសភា។

## ជំពូកទី ៣៖ អំពីគណៈកម្មាធិការអចិន្ត្រៃយ៍ និង គណៈកម្មការនានានៃរដ្ឋសភា

ប្រការ១០ ថ្មី (ពីរ) ចែងថា ក្នុងករណីធម្មតា រដ្ឋសភាត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវសមាជិកគណៈកម្មការនានានៃរដ្ឋសភា។ គណៈកម្មការនីមួយៗ ត្រូវជ្រើសតាំងប្រធានមួយរូប អនុប្រធានមួយរូប និងលេខាធិការមួយរូបដោយវិធីបោះឆ្នោត។ ប៉ុន្តែក្នុងករណីដែលស្ថានភាពនយោបាយតម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ការជ្រើសរើសប្រធាន និងអនុប្រធានគណៈកម្មការនានានៃរដ្ឋសភា ត្រូវអនុវត្តតាមចំណុចខ.២ នៃប្រការ២ ថ្មី (ពីរ)។ បន្ទាប់មករដ្ឋសភា អាចដំណើរការបន្តដើម្បីជ្រើសតាំងដាច់ដោយឡែកពីគ្នា នូវសមាជិកគណៈកម្មការនានានៃរដ្ឋសភា ដោយសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ តំណាងរាស្ត្រមួយរូបអាចជាសមាជិកពីរគណៈកម្មការបាន។

ប្រការ១០ ថ្មី (ពីរ)នេះ មិនបានចែងឲ្យបានច្បាស់លាស់អំពីចំនួនសម្លេង ដែលត្រូវទទួលបានក្នុងការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនៃរដ្ឋសភាឡើយ។ គេមិនដឹងថា តើការបោះឆ្នោតនេះ ត្រូវធ្វើឡើងដោយមតិភាគច្រើនដាច់ខាត ឬមតិភាគច្រើនពីរភាគបី ឬយ៉ាងណាឡើយ។ ប៉ុន្តែក្នុងស្ថានភាពនយោបាយតម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែម ប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភាកើតចេញពីការបោះឆ្នោតជ្រើសតាំងជាកញ្ចប់។ បទបញ្ញត្តិនេះ គឺផ្ទុយនឹងគោលការណ៍នីត្យានុកូលភាព(2)។

តំណាងរាស្ត្រមួយរូប អាចជាសមាជិកពីរគណៈកម្មការបាន។ ការណ៍នេះអាចនាំឲ្យតំណាងរាស្ត្រមិនអាចបំពេញការងាររបស់ខ្លួនឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធិភាពឡើយ ជាពិសេសនៅក្នុងខណៈដែលតួនាទីរបស់គណៈកម្មការទាំងអស់ ត្រូវបានលើកកម្ពស់តំណាងរាស្ត្រម្នាក់ មិនអាចបំពេញការងារនៅក្នុងគណៈកម្មការពីរ ដែលមានកាលវិភាគធ្វើការក្នុងពេលជាមួយគ្នានោះឡើយ។

បន្ថែមពីលើនេះ យោងតាមបទបញ្ជាផ្ទៃក្នុងនេះ គេមិនឃើញគណៈកម្មការរដ្ឋសភាមានតួនាទីសកម្មក្នុងការជម្រុញឲ្យមានតម្លាភាព ទំនួលខុសត្រូវ ការត្រួតពិនិត្យ និងតុល្យភាពឡើយ។ យោងតាមបទបញ្ជាផ្ទៃក្នុងនេះ គណៈកម្មការរដ្ឋសភាមានតួនាទីត្រួតពិនិត្យលើសេចក្តីព្រាង[3] តែការត្រួតពិនិត្យនោះមិនត្រូវបានធ្វើជាសាធារណៈឡើយ ហើយគណៈកម្មការរដ្ឋសភាហាក់ដូចជាគ្មានតួនាទីត្រួតពិនិត្យមើលសេចក្តីស្នើច្បាប់ដោយតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាឡើយ(4)។ ការណ៍នេះ គឺមិនស្របនឹងគោលការណ៍

---

(2) *សូមមើល* សេចក្តីពន្យល់ខាងលើទាក់ទងនឹងប្រការ ១០ ថ្មី (ពីរ)។

(3) *សូមមើល* ប្រការ ២១ នៃបទបញ្ជាផ្ទៃក្នុង។

(4) *ដូចខាងលើ។ សូមមើលផងដែរ* ប្រការ ២២ នៃបទបញ្ជាផ្ទៃក្នុង។

តម្លាភាព និងទំនួលខុសត្រូវឡើយ។ យោងតាមបទបញ្ជាផ្ទៃក្នុងនេះដែរ គេក៏មិនឃើញគណៈកម្មការរដ្ឋសភាមានសិទ្ធិកោះហៅសមាជិករដ្ឋាភិបាល និងជនដែលពាក់ព័ន្ធដទៃទៀត មកសាកសួរអំពីសេចក្តីព្រាងច្បាប់ ឬសេចក្តីព្រាងច្បាប់ ឬការអនុវត្តច្បាប់ ដែលតម្រូវដោយគោលការណ៍ត្រួតពិនិត្យ និងតុល្យភាពរវាងអំណាចគ្រប់គ្រងរដ្ឋឡើយ។

## ជំពូកទី ៤៖ អំពីអគ្គលេខាធិការដ្ឋាន

ប្រការ១៥ ថ្មី (ពីរ) ចែងថា អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។ អគ្គលេខាធិការ និងអគ្គលេខាធិការរងត្រូវជ្រើសតាំងក្នុងចំណោមមន្ត្រីជាន់ខ្ពស់ មានបទពិសោធន៍ក្នុងកិច្ចការរដ្ឋបាលយ៉ាងតិចដប់ឆ្នាំ ហើយដែលមិនមែនជាសមាជិករដ្ឋសភា និងមិនមែនជាអ្នកដឹកនាំក្នុងគណបក្សនយោបាយមួយ។ ប្រការនេះ មិនបានបញ្ជាក់ចំនួនអគ្គលេខាធិការរងឲ្យបានច្បាស់លាស់ឡើយ។

ប្រការ១៧ ថ្មី ចែងថា បុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋាន ត្រូវតែងតាំងដោយប្រធានរដ្ឋសភាស្របតាមច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ។ នៅខណៈដែលរដ្ឋសភា គឺជាវេទិកាដែលជំរុញឲ្យមានការចូលរួមមតិពីគ្រប់គណបក្សនយោបាយទាំងអស់ ការតែងតាំងបុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋានដោយប្រធានរដ្ឋសភា គឺមិនឆ្លុះបញ្ចាំងអំពីតួនាទីប្រធានរដ្ឋសភា ដែលជាអ្នក សម្របសម្រួលកិច្ចការគោលនយោបាយ តែមិនមែនជាអ្នកទទួលខុសត្រូវការងាររបស់អគ្គលេខាធិការទេ។ បន្ថែមពីលើនេះ ការធ្វើរបៀបនេះ ក៏បង្កឲ្យមានការបម្រើផលប្រយោជន៍ផ្តាច់មុខរបស់គណបក្សមួយ ក្នុងការតែងតាំងបុគ្គលិកទាំងនោះ ធ្វើឲ្យរាំងស្ទះដល់ការងាររួមរបស់រដ្ឋសភា។

ប្រការ១៨ ចែងថា កំណត់ហេតុទាំងអស់ និងឯកសារដទៃទៀតរបស់រដ្ឋសភា ត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋាន ហើយមិនត្រូវធ្វើឲ្យបែកខ្ចរខ្ចាយទៅខាងក្រៅ ដោយគ្មានការអនុញ្ញាតពីប្រធានឡើយ។ បទបញ្ញត្តិនេះ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គោលការណ៍តម្លាភាព និងទំនួលខុសត្រូវ ដែលតម្រូវឲ្យម្ចាស់ឆ្នោតទទួលបានព័ត៌មានពេញលេញអំពីដំណើរការគ្រប់គ្រងរដ្ឋ ដែលក្នុងករណីនេះ គឺដំណើរការរដ្ឋសភា ហេតុនេះផ្តល់លទ្ធភាពឲ្យម្ចាស់ឆ្នោត ទាមទារបាននូវការទទួលខុសត្រូវពីសំណាក់តួអង្គគ្រប់គ្រងរដ្ឋទាំងនេះ([5])។ ដូច្នេះ វិធានផ្ទៃក្នុងនៃរដ្ឋសភានេះ មិនបានចែងអំពីបទបញ្ជារដ្ឋបាល សម្រាប់ជួយសម្រួលដល់សាធារណជនក្នុងការទទួលបានព័ត៌មានទាំងនេះឡើយ។

## ជំពូកទី ៦៖ អំពីសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់

ប្រការ២១ ចែងថាសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាលត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។ សេចក្តីព្រាងច្បាប់នោះ ជាលិខិតលាយលក្ខណ៍អក្សរ ហើយត្រូវចែកជូនអ្នកតំណាងរាស្ត្រទាំងអស់ព្រមទាំងសេចក្តីថ្លែងហេតុមកជាមួយផង។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បញ្ជូនសេចក្តីព្រាងនោះទៅគណៈកម្មការតាមមុខជំនាញឲ្យពិនិត្យ។ កាលបើពិនិត្យរួចហើយ ប្រធាននៃគណៈកម្មការនោះ ត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនរដ្ឋសភា។ ប៉ុន្តែបទបញ្ជាផ្ទៃក្នុងនេះ បានចែងដាច់ដោយឡែក

---

([5]) មាត្រា ៣៥ កថាខណ្ឌ ១ នៃរដ្ឋធម្មនុញ្ញកម្ពុជា៖ "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាព នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ"។

ក្នុងប្រការ២២ អំពីសេចក្តីស្នើច្បាប់ដែលចែងថា សេចក្តីស្នើច្បាប់ដែលតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាជាអ្នកធ្វើនោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរចែកជាមាត្រា ហើយមានសេចក្តីថ្លែងហេតុនៅខាងដើមជាប់មកជាមួយផង។ តាមរយៈបទបញ្ញត្តិទាំងនេះ សេចក្តីស្នើច្បាប់ដោយតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា គឺមិនតម្រូវឲ្យឆ្លងកាត់ការត្រួតពិនិត្យរបស់គណៈកម្មការជំនាញរដ្ឋសភាឡើយ។

ប្រការ២៣ ចែងថា អ្នកតែងសេចក្តីស្នើច្បាប់មានសិទ្ធិចូលរាយការណ៍ជម្រាបគណៈកម្មការដែលពិនិត្យសេចក្តីស្នើនោះ។ ប៉ុន្តែប្រការនេះ មិនបានចែងអំពីតួនាទីរបស់គណៈកម្មការរដ្ឋសភា ក្នុងការកោះហៅជនពាក់ព័ន្ធឲ្យចូលរួមបំភ្លឺសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នៅក្នុងសវនាការសាធារណៈនោះឡើយ។ ការបើកសវនាការសាធារណៈ គឺជាកត្តាមួយសំខាន់នៃគោលការណ៍តម្លាភាព និងទំនួលខុសត្រូវ។

ប្រការ២៤ ផ្តល់សិទ្ធិឲ្យគណៈកម្មការអាចសន្និដ្ឋានឲ្យរដ្ឋសភាលើកចោល ឬទទួលពិចារណា [សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់] ឲ្យរដ្ឋសភាបញ្ចេញមតិជាមុន ឲ្យរដ្ឋសភាទទួលពិចារណា ហើយនឹងទុកជាការប្រញាប់ផងក៏បាន។ ប៉ុន្តែបទបញ្ជាផ្ទៃក្នុង មិនបានផ្តល់សិទ្ធិរបស់តំណាងរាស្ត្រ ដែលមិនមែនជាសមាជិកគណៈកម្មការឲ្យមានសម្លេងក្នុងការសម្រេច ឬស្នើឲ្យមានការត្រួតពិនិត្យលើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ក្នុងរបៀបវារៈសភាពេញអង្គឡើយ ក្នុងករណីដែលគណៈកម្មការសន្និដ្ឋានឲ្យរដ្ឋសភាច្រានចោលការពិចារណាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាមួយនោះ។

**ជំពូកទី ៩៖ អំពីសំណួរ និងចម្លើយ**

ប្រការ៣២ ចែងថា រាជរដ្ឋាភិបាល ត្រូវផ្តល់ចម្លើយទៅនឹងសំណួរ ដែលចោទសួរដោយអ្នកតំណាងរាស្ត្រ ក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ។ ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភា អាចសម្រេចបើកឲ្យមាន ឬមិនឲ្យមានការជជែកដេញដោល។ បើគ្មានការបើកឲ្យជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីនឹងបញ្ចប់សំណួរតែម្តង។ ប្រការនេះបានបិទសិទ្ធិ មិនឲ្យមានការឆ្លើយតបទៅនឹងចម្លើយជាលាយលក្ខណ៍អក្សររបស់រាជរដ្ឋាភិបាល និងមិនបានចែងអំពីការផ្តល់ពេលវេលាស្មើគ្នាក្នុងការផ្តល់ចម្លើយ និងឆ្លើយតបទៅនឹងចម្លើយនោះទាំងជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ឡើយ។ ការណ៍នេះ គឺមិនបានធានាការពារដល់សិទ្ធិចូលរួមមតិយោបល់របស់គណបក្សនយោបាយ ដែលមានសម្លេងភាគតិចឡើយ។

ប្រការ៣៣ ថ្មី ចែងថា បើសំណួរ [របស់អ្នកតំណាងរាស្ត្រ] ចំលើយនាយករដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី ឬតំណាងក្នុងករណីនាយករដ្ឋមន្ត្រីមានធុរៈ ត្រូវមកឆ្លើយសំណួរ។ ប៉ុន្តែបើសំណួរ ចំលើយសមាជិករាជរដ្ឋាភិបាលរូបណា សមាជិករូបនោះត្រូវមកឆ្លើយសំណួរនៅរដ្ឋសភា។ សមាជិករាជរដ្ឋាភិបាល គ្មានសិទ្ធិចាត់តំណាងមកឆ្លើយសំណួរនៅរដ្ឋសភាជំនួសខ្លួនឡើយ។ ធ្វើរបៀបនេះ អ្នកដែលកាន់ការងារជំនាញផ្ទាល់នឹងមិនអាចឡើងមកឆ្លើយសំណួរនៅរដ្ឋសភាបានឡើយ ដោយហេតុថា សមាជិករាជរដ្ឋាភិបាល ត្រូវឡើងមកឆ្លើយដោយខ្លួនឯងផ្ទាល់នូវគ្រប់បញ្ហាទាំងអស់។

## ជំពូកទី ១២៖ អំពីរបៀបប្រជុំ

ប្រការ ៤៨ថ្មី (ពីរ) ចែងថា អសនានុក្រមនៃក្រុមតំណាងរាស្ត្រត្រូវរៀបចំជាក្រុមៗ ដែលមានសមាជិកយ៉ាងតិចដប់រូប។ គណបក្សនយោបាយមានអាសនៈតិចជាងដប់ ត្រូវជ្រើសរើស ក្រុមដែលខ្លួនពេញចិត្តនៅជាមួយ។ យោងតាមមាត្រ ៥៥ ថ្មី មានតែតំណាងរាស្ត្រក្នុងក្រុមទេ ដែលត្រូវបានផ្តល់ពេលវេលាក្នុងការសំដែងមតិក្នុងការប្រជុំពេញអង្គរដ្ឋសភា។ ការមិនអនុញ្ញាតឲ្យតំណាងរាស្ត្រ ដែលមកពីគណបក្សមានអាសនតិចជាង១០ បង្កើតក្រុមដើម្បីមានឱកាសសំដែងមតិរបស់ខ្លួនក្នុងអង្គប្រជុំ គឺរំលោភលើគោលការណ៍គោរពមតិភាគតិច។ ប្រសិនបើ សមាជិកសភានៃគណបក្សដែលមានអាសនៈតិចជាងដប់ ចូលរួមជាមួយក្រុមសមាជិកសភាគណបក្សផ្សេង ការទទួលបានឱកាស និងរយៈពេល សំដែងមតិរបស់ក្រុមសមាជិកសភានៃគណបក្សដែលមានអាសនៈតិចជាងដប់ គឺស្ថិតនៅក្រោមការគ្រប់គ្រង់ និងចាត់ចែងនៃប្រធានក្រុមសមាជិកសភា។ ផ្អែកតាមស្មារតី មាត្រា៥១ នៃរដ្ឋធម្មនុញ្ញ(6) សមាជិកសភានៃគណបក្សដែលមានអាសនៈតិចជាងដប់ ត្រូវបានអនុញ្ញាតឲ្យបង្កើតមួយដាច់ដោយឡែក ដើម្បីមានឱកាសសំដែងមតិក្នុងអង្គប្រជុំ។

## ជំពូកទី ១៦៖ អំពីការសុំកែប្រែបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

ប្រការ៨២ចែងថា បទបញ្ជាផ្ទៃក្នុងនេះនឹងកែប្រែបាន លុះត្រាតែមានសេចក្តីស្នើសុំពីអ្នកតំណាងរាស្ត្រមួយភាគបួនយ៉ាងតិច នៃចំនួនសមាជិករដ្ឋសភាទាំងមូល ហើយត្រូវបានអនុម័តយល់ព្រមដោយសំឡេងពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ការស្នើសុំឲ្យមានការកែប្រែនេះ គួរតែធ្វើយ៉ាងណាឲ្យមានការចូលរួមពីសំណាក់គ្រប់គណបក្សនយោបាយកាន់អំណាច និងគណបក្សនយោបាយប្រឆាំង ព្រោះថា ច្បាប់នេះ ត្រូវឆ្លុះបញ្ចាំងពីឆន្ទៈនៃគណបក្សនយោបាយទាំងអស់ ដែលបង្កើតបានជារបបប្រជាធិបតេយ្យសេរីពហុបក្ស។ ក្នុងករណីមិនបានទទួលការអនុម័តមតិពីរភាគបី បទបញ្ជាផ្ទៃក្នុងអាណត្តិចុងក្រោយត្រូវបានចូលជាធរមាន។

អាស្រ័យហេតុនេះ តម្រូវឲ្យមានការកែប្រែមាត្រា៨២ថ្មីនៃរដ្ឋធម្មនុញ្ញកម្ពុជា ដើម្បីពង្រឹងបទបញ្ជាផ្ទៃក្នុងនេះ។

## មាត្រា ១២០ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ពីរចំណុចនៃមាត្រា១២០ថ្មី នៃវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានប៉ះពាល់ខ្លាំងដល់ សិទ្ធិអំណាច និងការបាត់បង់សមាជិករដ្ឋសភា ដែលផ្តល់ឲ្យគណបក្សសាមីនៃតំណាងរាស្ត្រមានអំណាចហួសហេតុ ក្នុងការដក ឬដាក់សមាជិករដ្ឋសភា ដោយគ្មានតម្លាភាព និងគ្មានមូលហេតុគ្រប់គ្រាន់។

ចំណុចទីមួយ «សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសភាជិករដ្ឋសភា»។ ចំណុចទីពីរ «សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សខ្លួន។ ចំណុចទាំងពីរនៃច្បាប់នេះ មិនអនុវត្តត្រឹមត្រូវតាមមាត្រា៧៧នៃរដ្ឋធម្មនុញ្ញដែលចែងថា «អាណត្តិអាជ្ញាបញ្ជាទាំងឡាយ ចំពោះតំណាងរាស្ត្រក្នុងរដ្ឋសភា ត្រូវទុកជាមោឃៈ។ តំណាងរាស្ត្រជាតំណាងប្រជាជាតិខ្មែរ មិនមែនតំណាងគណបក្សនយោបាយណាមួយទេ»។

(6) ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។

## ជំពូកទី ១៥ នៃវិសោធនកម្មនៃរដ្ឋធម្មនុញ្ញ ឬ/និងមាត្រា១១៨ នៃច្បាប់បោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ

ចំណុច ខ មាត្រា១១៨នៃច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានបង្ហាញថា គណៈកម្មាធិការជាតិរៀបចំកាបោះឆ្នោត ប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ។ ផ្អែកលើការអនុវត្តន៍បែបនេះ កន្លងមក មានការបកស្រាយខុសៗគ្នាអំពីសុពលភាពរបស់តំណាងរាស្ត្រ។ ដើម្បីដោះស្រាយបញ្ហានេះ ជំពូកទី១៥ ស្ដីពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នៃវិសោធនកម្មរដ្ឋធម្មនុញ្ញ ឬ/និងមាត្រា១១៨ នៃច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបញ្ជាក់ពីសិទ្ធិ និងអំណាចរបស់ (គ.ជ.ប) ក្នុងការប្រកាសពីសុពលភាពតំណាងរាស្ត្រ ដើម្បីឲ្យរដ្ឋសភាចាប់ផ្ដើមនីតិកាលថ្មីរបស់ខ្លួនដោយស្របមាត្រា៧៦ នៃរដ្ឋធម្មនុញ្ញ([7])។

## ១. សេចក្ដីស្នើវិសោធនកម្មមាត្រា៨២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

| អត្ថបទដើម | អត្ថបទស្នើ |
|---|---|
| **មាត្រា ៨២ ថ្មី៖**<br>រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។<br>មុនចាប់ផ្ដើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗត្រូវបោះឆ្នោតដាច់ដោយឡែក ពីគ្នានូវប្រធាន អនុប្រធានរដ្ឋសភា និង សមាជិកទាំងអស់ នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>រដ្ឋសភា ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ | **មាត្រា ៨២ ថ្មី (មួយ)៖**<br>រដ្ឋសភា បើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។<br>មុនចាប់ផ្ដើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង«ថ្មី» ដោយមតិពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ក្នុងករណីមិនអាចអនុម័តបទបញ្ជាផ្ទៃក្នុង«ថ្មី»បាននោះ បទបញ្ជាផ្ទៃក្នុងនៃអាណត្តិចុងក្រោយត្រូវចូលជាធរមាន។ |
| **មាត្រា ១១៩ ថ្មី៖**<br>តាមសេចក្ដីស្នើពីប្រធាន ដោយមានមតិ | **មាត្រា ១១៩ ថ្មី (មួយ)៖**<br>តាមសេចក្ដីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុ |

([7]) រដ្ឋសភា មានសមាជិកតំណាងរាស្ត្រយ៉ាងតិច១២០រូប។

| | |
|---|---|
| ឯកភាពពីអនុប្រធានទាំងពីរ នៃរដ្ឋសភា ព្រះមហាក្សត្រ ទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រ នៃគណបក្ស ដែលឈ្នះឆ្នោត ឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្ទួផ្ទងឱ្យកាន់តំណែងផ្សេងៗ ក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។<br>កាលបើរដ្ឋសភា បានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យ តែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។<br>មុនចូលកាន់តំណែងគណៈរដ្ឋមន្ត្រី ត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៦។ | ប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោតឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជន ដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្ទួផ្ទងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។<br>វីរជនមួយរូប ជាបេក្ខជននាយករដ្ឋមន្ត្រី មិនត្រូវជាបេក្ខជនដែលធ្លាប់កាន់តំណែងជានាយករដ្ឋមន្ត្រីចំនួនពីរ(០២) អាណត្តិ ឬរយៈពេលដប់(១០) ឆ្នាំកន្លងមកហើយ។<br>មុនចូលកាន់តំណែងគណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៦។ |
| | **ជំពូកថ្មី ស្តីពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (បញ្ចូលក្នុងរដ្ឋធម្មនុញ្ញ)**<br>[……]<br>យ៉ាងយូរបី(០៣)ថ្ងៃក្រោយពេលការប្រកាសលទ្ធផល បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាស្ថាពរ គណៈកម្មាធិការជាតិសម្រាប់ការបោះឆ្នោត ត្រូវរៀបចំបញ្ជីសមាជិកតំណាងរាស្ត្រ ដែលមានយ៉ាងតិច១២០រូបថ្វាយព្រះមហាក្សត្រ។ |

## ២. សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

### ជំពូកទី១
### អំពីការិយាល័យបណ្តោះអាសន្ន និងភារកិច្ច

| **អត្ថបទដើម** | **អត្ថបទស្នើ** |
| --- | --- |
| **ប្រការ ២ ថ្មី (ពីរ)៖ [...]** | **ប្រការ ២ ថ្មី (បី) ៖ [...]** |
| ក. ក្នុងករណីធម្មតា ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិក រដ្ឋសភាខាងលើនេះ ប្រសិនបើមានកូរ៉ុម លើសពីពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភា ត្រូវចាប់ផ្ដើមធ្វើការតាមរបៀបវារៈដូចតទៅ៖ | ក. ក្នុងករណីធម្មតា ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិក រដ្ឋសភាខាងលើនេះ ប្រសិនបើ មានកូរ៉ុមលើសពីពាក់កណ្ដាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភា ត្រូវចាប់ផ្ដើមធ្វើការតាមរបៀបវារៈដូចតទៅ៖ |
| ១. សម្រេចអំពីសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ។ | ១. សម្រេចអំពី សុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ។ |
| ២. បោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានទាំងពីររបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ | ២. បោះឆ្នោតជ្រើសរើសជាកញ្ចប់ នូវប្រធានអនុប្រធានទាំងពីររបស់រដ្ឋសភាដែលមានសមាសភាពបុរស និងស្ត្រី សមាមាត្រតាមសម្លេងឆ្នោតដែលគណបក្សនយោបាយនីមួយៗ ទទួលបាន ដោយមតិភាគដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ |
| មិនអាចជជែកពិភាក្សាអ្វីឡើយ នៅក្រោមអធិបតីភាពរបស់ព្រឹទ្ធសមាជិក។ | មិនអាចជជែកពិភាក្សាអ្វីឡើយ នៅក្រោមអធិបតីភាពរបស់ព្រឹទ្ធសមាជិក។ |
| តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ។ | តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ។ |
| ខ. ក្នុងករណី ដែលមានស្ថានភាពនយោបាយតម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានា នូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ក្រោមការដឹកនាំរបស់ ព្រឹទ្ធសមាជិករដ្ឋសភាខាងលើនេះ ប្រសិនបើ មានកូរ៉ុមលើសពីពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភាត្រូវចាប់ផ្ដើម ធ្វើការតាមរបៀបវារៈដូចតទៅ៖ | ខ. ក្នុងករណីដែលមានស្ថានភាពនយោបាយ តម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិករដ្ឋសភាខាងលើនេះ ប្រសិនបើ មានកូរ៉ុមលើសពីពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភាត្រូវចាប់ផ្ដើមធ្វើការតាមរបៀបវារៈដូចតទៅ៖ |
| ១. សម្រេចសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ។ | ១. សម្រេចសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ។ |
| ២. បោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំង ប្រធាន អនុប្រធាន រដ្ឋសភា ប្រធានអនុប្រធានគណៈកម្មការជំនាញទាំងអស់ នៃរដ្ឋសភា និងផ្ដល់សេចក្ដីទុកចិត្ត ចំពោះរាជរដ្ឋា | ២. បោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំង ប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា និងផ្ដល់សេចក្ដីទុកចិត្តចំពោះរាជរដ្ឋាភិបាល នៅដើមនីតិកាលនីមួយៗ ដោយវិធីលើកដៃ និងដោយសម្លេងភាគច្រើនដាច់ខាតនៃ |

| | |
|---|---|
| ភិបាលនៅដើមនីតិកាលនីមួយៗ ដោយវិធីលើកដៃ និងដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។<br>មិនអាចជជែកពិភាក្សាអ្វីឡើយ នៅក្រោមអធិបតីភាពរបស់ព្រឹទ្ធសមាជិក។<br>តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥នៃរដ្ឋធម្មនុញ្ញ។ | សមាជិករដ្ឋសភាទាំងមូល។<br><br>មិនអាចជជែកពិភាក្សាអ្វីឡើយនៅក្រោមអធិបតីភាពរបស់ព្រឹទ្ធសមាជិក។<br>តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ។<br>តំណែងអនុប្រធានរដ្ឋសភាម្នាក់ ត្រូវបានប្រគល់ឲ្យគណបក្សមិនចូលរួមក្នុងរាជរដ្ឋាភិបាល ដែលមានអាសនៈច្រើនជាងគេ។ |

## ជំពូកទី ៣
## អំពីគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានានៃរដ្ឋសភា

| អត្ថបទដើម | អត្ថបទស្នើ |
|---|---|
| **ប្រការ ១០ ថ្មី (ពីរ)៖**<br>ក្នុងករណីធម្មតា រដ្ឋសភាត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវសមាជិកគណៈកម្មការនានានៃរដ្ឋសភា។ គណៈកម្មការនីមួយៗ ត្រូវជ្រើសតាំងប្រធានមួយរូប អនុប្រធានមួយរូប និងលេខាធិការមួយរូប ដោយវិធីបោះឆ្នោត។<br>ក្នុងករណីដែលស្ថានភាពនយោបាយ តម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ការជ្រើសរើសប្រធាន និងអនុប្រធានគណៈកម្មការនានានៃរដ្ឋសភាត្រូវអនុវត្តតាមចំណុច ខ.២ នៃប្រការ២ ថ្មី (ពីរ)។ បន្ទាប់មករដ្ឋសភាអាចដំណើរការបន្ត ដើម្បីជ្រើសតាំងដាច់ដោយឡែកពីគ្នា នូវសមាជិកគណៈកម្មការនានានៃរដ្ឋសភា ដោយសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ | **ប្រការ ១០ ថ្មី (បី) ៖**<br>ក្នុងករណីធម្មតា រដ្ឋសភាត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវសមាជិកគណៈកម្មការនានានៃរដ្ឋសភា។ គណៈកម្មការនីមួយៗ ត្រូវជ្រើសតាំងប្រធានមួយរូប អនុប្រធានមួយរូប និងលេខាធិការមួយរូប ដោយវិធីបោះឆ្នោត។<br><br>គណបក្សដឹកនាំរាជរដ្ឋាភិបាល ទទួលតួនាទីដឹកនាំគណៈកម្មការ មានចំនួនស្មើនឹងចំនួនគណៈកម្មការដឹកនាំដោយគណបក្សមានអាសនៈក្នុងរដ្ឋសភា ដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល។ គណបក្សមិនចូលរួមក្នុងរាជរដ្ឋាភិបាលបែងចែកចំនួនកម្មការ ដែលមានតួនាទី ដឹកនាំរបស់ខ្លួន ទៅតាមសមាមាត្រនៃអាសនៈមាននៅក្នុងរដ្ឋសភា ដល់គណបក្សមិនចូលរួមក្នុងរាជរដ្ឋាភិបាលនីមួយៗ<br>ក្នុងករណីដែលស្ថានភាពនយោបាយ តម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជា |

| | |
|---|---|
| [...]<br>កូរ៉ុមសម្រាប់ប្រជុំគណៈកម្មការនានា ត្រូវឲ្យមានលើសពីពាក់កណ្តាលនៃចំនួនសមាជិក។<br>គណៈកម្មការនីមួយៗ មានសមាជិកយ៉ាងតិចប្រាំពីររូប។ តំណាងរាស្ត្រមួយរូប អាចជាសមាជិកពីរគណៈកម្មការបាន។ | ប្រក្រតីនៃស្ថាប័នជាតិ ការជ្រើសរើសប្រធាន និងអនុប្រធានគណៈកម្មការនានានៃរដ្ឋសភា ត្រូវអនុវត្តតាមចំណុច ខ.២ នៃប្រការ ២ ថ្មី (ពីរ)។ បន្ទាប់មករដ្ឋសភាអាចដំណើរការបន្ត ដើម្បីជ្រើសតាំងដាច់ដោយឡែកពីគ្នា នូវសមាជិកគណៈកម្មការនានានៃរដ្ឋសភា ដោយសម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>កូរ៉ុមសម្រាប់ប្រជុំគណៈកម្មការនានា ត្រូវឲ្យមានលើសពីពាក់កណ្តាលនៃចំនួនសមាជិក។<br>គណៈកម្មការនីមួយៗ មានសមាជិកយ៉ាងតិចប្រាំពីររូប។ តំណាងរាស្ត្រមួយរូប មិនអាចជាសមាជិកលើសពីមួយគណៈកម្មការទេ។ |
| | **ប្រការ ថ្មី (បញ្ចូលក្នុងជំពូកទី ៣ អំពីគណៈកម្មាធិការអចិន្ត្រៃយ៍ និង គណៈកម្មការនានានៃរដ្ឋសភា)៖**<br>គណៈកម្មាធិការអចិន្ត្រៃយ៍ ឬគណៈកម្មការជំនាញនីមួយៗនៃរដ្ឋសភា ត្រូវកំណត់ពេល១(មួយ)ថ្ងៃ ក្នុង១(មួយ)សប្តាហ៍ ដើម្បីធ្វើសវនាការសាធារណៈ ជជែកដេញដោល ដោយកោះហៅជនពាក់ព័ន្ធមកបំភ្លឺលើសេចក្តីព្រាង និងសេចក្តីស្នើច្បាប់ និងការអនុវត្តច្បាប់ជាធរមាន។<br>ទោះបីជាយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ។<br>គណៈកម្មាធិការអចិន្ត្រៃយ៍ មានអំណាចទទួលពិនិត្យបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។ |

## ជំពូកទី ៤
## អំពីអគ្គលេខាធិការដ្ឋាន

| អត្ថបទដើម | អត្ថបទស្នើ |
|---|---|
| ប្រការ ១៥ ថ្មី (ពីរ)៖ | ប្រការ ១៥ ថ្មី (បី) ៖ |

| | |
|---|---|
| អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។<br>អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវជ្រើសតាំងក្នុងចំណោមមន្ត្រីជាន់ខ្ពស់ មានបទពិសោធន៍ក្នុងកិច្ចការរដ្ឋបាល យ៉ាងតិចដប់ឆ្នាំ ហើយដែលមិនមែនជាសមាជិករដ្ឋសភា និងមិនមែនជាអ្នកដឹកនាំក្នុងគណបក្សនយោបាយមួយ។ | អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងចំនួនពីររូប។ អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវជ្រើសតាំងដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងចំណោមមន្ត្រីជាន់ខ្ពស់មានបទពិសោធន៍ ក្នុងកិច្ចការរដ្ឋបាលយ៉ាងតិចដប់ឆ្នាំ ហើយដែលមិនមែនជាសមាជិករដ្ឋសភា និងមិនមែនជាអ្នកដឹកនាំ ឬមន្ត្រីក្នុងគណបក្សនយោបាយមួយ។ |
| **ប្រការ ១៧ ថ្មី៖**<br>បុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋាន ត្រូវតែងតាំងដោយប្រធានរដ្ឋសភាស្របតាមច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ។ | **ប្រការ ១៧ ថ្មី (មួយ)៖**<br>បុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋាន ត្រូវតែងតាំងដោយអគ្គលេខាធិការនៃរដ្ឋសភា ស្របតាមច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ។ |
| **ប្រការ ១៨៖**<br>កំណត់ហេតុទាំងអស់ និងឯកសារដទៃទៀតរបស់រដ្ឋសភា ត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋាន ហើយមិនត្រូវធ្វើឲ្យបែកខ្ញែកខ្ចាយទៅខាងក្រៅ ដោយគ្មានការអនុញ្ញាតពីប្រធានឡើយ។ | **ប្រការ ១៨ ថ្មី ៖**<br>កំណត់ហេតុទាំងអស់ និងឯកសារដទៃទៀតរបស់រដ្ឋសភា ត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋាន និងជាសាធារណៈ លើកលែងតែកំណត់ហេតុ និងឯកសារទាំងឡាយណា ដែលសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍ថា អាចប៉ះពាល់ដល់សន្តិសុខជាតិ។ |
| | **ប្រការថ្មី (បញ្ចូលទៅក្នុងជំពូកទី ៤ អំពីអគ្គលេខាធិការដ្ឋាន) ៖**<br>អគ្គលេខាធិការដ្ឋាន ត្រូវរៀបចំឲ្យមានបទបញ្ជារដ្ឋបាល ដើម្បីធានាសិទ្ធិប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន និងចូលរួមក្នុងព្រឹត្តិការណ៍សាធារណៈរបស់រដ្ឋសភា។ |

## ជំពូកទី ៦
## អំពីសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់

| អត្ថបទដើម | អត្ថបទស្នើ |
|---|---|
| **ប្រការ ២៣៖**<br>អ្នកតែងសេចក្តីស្នើច្បាប់ មានសិទ្ធិចូលរាយការណ៍ជម្រាបគណៈកម្មការ ដែលពិនិត្យ | **ប្រការ ២៣ ថ្មី៖**<br>គណៈកម្មការជំនាញនៃរដ្ឋសភា ត្រូវកោះហៅអ្នកព្រាងច្បាប់ និងអ្នកស្នើច្បាប់មកសាកសួរ អំពីសេចក្តីព |

| | |
|---|---|
| សេចក្តីស្នើនោះ។ | ព្រាង និងសេចក្តីស្នើច្បាប់ក្នុងសវនាការសាធារណៈ។ អ្នកតែងព្រាងច្បាប់ ឬអ្នកតែងសេចក្តីស្នើច្បាប់មានសិទ្ធិចូលរាយការណ៍ជម្រាបគណៈកម្មការ ដែលពិនិត្យសេចក្តីស្នើនោះ។ |
| **ប្រការ ២៤៖**<br>គណៈកម្មការអាចសន្និដ្ឋានថា៖<br>• សូមឲ្យរដ្ឋសភាលើកចោល ពុំពិចារណាក៏បាន។<br>• សូមឲ្យរដ្ឋសភាបញ្ចេញមតិជាមុនសិន តើគួរទទួលពិចារណា ឬទេ។<br>• សូមឲ្យរដ្ឋសភាទទួលពិចារណា ហើយនឹងទុកជាការប្រញាប់ផងក៏បាន។ | **ប្រការ ២៤ ថ្មី៖**<br>គណៈកម្មការអាចសន្និដ្ឋានថា៖<br>• សូមឲ្យរដ្ឋសភាលើកចោលពុំពិចារណាក៏ បាន។<br>• សូមឲ្យរដ្ឋសភាបញ្ចេញមតិជាមុនសិនតើគួរទទួលពិចារណា ឬទេ។<br>• សូមឲ្យរដ្ឋសភាទទួលពិចារណា ហើយនឹងទុកជាការប្រញាប់ផងក៏បាន។<br>សមាជិកយ៉ាងតិចមួយភាគបីនៃរដ្ឋសភាទាំងមូល មានសិទ្ធិសុំឲ្យរដ្ឋសភា សម្រេចផ្ទុយពីការសន្និដ្ឋានរបស់គណៈកម្មការ។ |

## ជំពូកទី ៩
## អំពីសំណួរ និង ចម្លើយ

| អត្ថបទដើម | អត្ថបទស្នើ |
|---|---|
| **ប្រការ ៣២៖**<br>អ្នកតំណាងរាស្ត្រមានសិទ្ធិដាក់សំណួរ ដល់រាជរដ្ឋាភិបាល។ សំណួរនេះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូន តាមរយៈប្រធានរដ្ឋសភា។<br>ចម្លើយ អាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើង ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន។<br>ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី | **ប្រការ ៣២ ថ្មី៖**<br>អ្នកតំណាងរាស្ត្រ មានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូន តាមរយៈប្រធានរដ្ឋសភា។<br>ចម្លើយ អាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូប អាស្រ័យដោយបញ្ហា ដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប។ បើបញ្ហា ពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រី ត្រូវឆ្លើយផ្ទាល់ខ្លួន។<br>ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីអាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ។<br>ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលដប់ប្រាំថ្ងៃ |

| | | |
|---|---|---|
| អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ។<br>ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ។<br>ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសម្រេចបើកឲ្យមាន ឬ មិនឲ្យមានការជជែកដេញដោល។ បើគ្មានការបើកឲ្យជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬ របស់នាយករដ្ឋមន្ត្រី នឹងបញ្ចប់សំណួរតែម្តង។ | បន្ទាប់ពីបានទទួលសំណួរ។<br>ចំពោះចម្លើយផ្ទាល់មាត់<br>ចំពោះចម្លើយជាលាយលក្ខណ៍អក្សរ តំណាងរាស្ត្រដាក់សំណួរ មានសិទ្ធិឆ្លើយតបផ្ទាល់មាត់ក្នុងរដ្ឋសភា ក្នុងរយៈពេលស្មើនឹង ការអានចម្លើយជាលាយលក្ខណ៍អក្សររបស់រាជរដ្ឋាភិបាល។ | |
| **ប្រការ ៣៣ ថ្មី៖**<br>តំណាងរាស្ត្រ ដែលបានតាំងសំណួរចំពោះរដ្ឋមន្ត្រីណាមួយ អាចសុំដកលិខិតតាំងសំណួររបស់ខ្លួនចេញបាន។<br>តំណាងរាស្ត្រឯទៀត អាចទទួលពាក្យសុំតាំងសំណួរដែលដកចេញហើយនោះ ទៅជូនប្រធានរដ្ឋសភាសាជាថ្មីទៀតបាន កាលបើយល់ឃើញថាចាំបាច់។<br>បើមានការបើកឲ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធនាយករដ្ឋមន្ត្រី អាចជជែកប្តូរយោបល់ ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ។<br>រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃ ក្នុងមួយសប្តាហ៍ សម្រាប់ចោទសួររាជរដ្ឋាភិបាល។ ការប្រជុំនេះមិនទាមទារកូរ៉ុមទេ។<br>បើសំណួរ ចំលើយនាយករដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី ឬតំណាងក្នុងករណីនាយករដ្ឋមន្ត្រីមានធុរៈ ត្រូវមកឆ្លើយសំណួរ។<br>បើសំណួរ ចំលើយសមាជិករាជរដ្ឋាភិបាលរូបណាសមាជិករូបនោះ ត្រូវមកឆ្លើយសំណួរនៅរដ្ឋសភា។<br>ទោះបីជាយ៉ាងណាក៏ដោយ សម័យប្រជុំសំរាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធ | **ប្រការ ៣៣ ថ្មី(មួយ)៖**<br>តំណាងរាស្ត្រដែលបានតាំងសំណួរចំពោះរដ្ឋមន្ត្រី ណាមួយ អាចសុំដកលិខិតតាំងសំណួររបស់ខ្លួនចេញបាន។<br>តំណាងរាស្ត្រឯទៀត អាចទទួលពាក្យសុំតាំងសំណួរដែលដកចេញហើយនោះ ទៅជូនប្រធានរដ្ឋសភាសាជាថ្មីទៀតបាន កាលបើយល់ឃើញថាចាំបាច់។<br>បើមានការបើកឲ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធ នាយករដ្ឋមន្ត្រីអាចជជែកប្តូរយោបល់ ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ។ រដ្ឋសភា កំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ សំរាប់ចោទសួររាជរដ្ឋាភិបាល។ ការប្រជុំនេះមិនទាមទារកូរ៉ុមទេ។<br>នាយករដ្ឋមន្ត្រី ឬសមាជិករាជរដ្ឋាភិបាល អាចមកឆ្លើយដោយផ្ទាល់ ឬចាត់តំណាងណាម្នាក់មកឆ្លើយចំពោះមុខរដ្ឋសភា។<br>ទោះបីជាយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឲ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ។ | |

| | |
|---|---|
| ភាព ឲ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ។ | |
| **ប្រការ ៣៥៖**<br>រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាល ពីដំណែងដោយអនុម័តញត្តិបន្ទោស តាមសម្លេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួន សាមសិបនាក់យ៉ាងតិច ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។ | **ប្រការ ៣៥ (ថ្មី)៖**<br>រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីដំណែង ដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រ ចំនួនសាមសិបនាក់យ៉ាងតិច ទើបរដ្ឋសភា អាចលើកមកពិភាក្សាបាន។<br>ប្រសិនបើមានញត្តិបន្ទោសសមាជិកគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាលពីរដង រដ្ឋសភាត្រូវបើកប្រជុំពេញអង្គពិភាក្សា និងអនុម័តជាសាធារណៈក្នុងទម្លាក់ សមាជិកគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាល។ |
| | **ប្រការថ្មី (បញ្ចូលទៅក្នុងជំពូកនេះ)**<br>គណបក្សដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និងមានអាសនៈច្រើនជាង នៅក្នុងរដ្ឋសភាត្រូវបានទទួលស្គាល់ហើយមានសិទ្ធិបង្កើតអ្នកនាំពាក្យ ក្នុងការត្រួតពិនិត្យការងាររបស់រាជរដ្ឋាភិបាល ហើយអាចស្នើសុំឲ្យមានកិច្ចពិភាក្សាតទល់លើគោលនយោបាយ របស់រដ្ឋាភិបាល និងមានសិទ្ធិឆ្លើយតបដោយផ្ទាល់មាត់ ឬជាលាយលក្ខអក្សរទៅនឹងចម្លើយរបស់រាជរដ្ឋាភិបាល ទៅនឹងសំណួររបស់តំណាងរាស្ត្រ។ |

## ជំពូកទី ១២
## អំពីរបៀបប្រជុំ

| អត្ថបទដើម | អត្ថបទស្នើ |
|---|---|
| **ប្រការ ៤៨ថ្មី(ពីរ)៖** [......]<br>គណៈបក្សនយោបាយ មានអាសនៈតិចជាងដប់ត្រូវជ្រើសរើសក្រុមណាមួយ ដែលខ្លួនពេញ | **ប្រការ ៤៨ថ្មី(បី)៖** [......]<br>គណៈបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភាតិចជាងដប់ មានសិទ្ធិបង្កើតក្រុមរបស់ខ្លួនចំនួនមួយ(០១)ក្រុម។ |

| | |
|---|---|
| ចិត្តនៅជាមួយ។ | |

**ជំពូកទី ១៦**

**អំពីការសុំកែប្រែបទបញ្ញាផ្ទៃក្នុងនៃរដ្ឋសភា**

| **អត្ថបទដើម** | **អត្ថបទស្នើ** |
|---|---|
| **ប្រការ ៨២ ថ្មី៖**<br>បទបញ្ញាផ្ទៃក្នុងនេះនឹងកែប្រែបាន លុះត្រាតែមានសេចក្ដីស្នើសុំពី អ្នកតំណាងរាស្ត្រមួយភាគបួនយ៉ាងតិច នៃចំនួនសមាជិករដ្ឋសភាទាំងមូល ហើយត្រូវបានអនុម័តយល់ព្រមដោយសម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ | **ប្រការ ៨២ ថ្មី(មួយ)៖**<br>បទបញ្ញាផ្ទៃក្នុងនេះនឹងកែប្រែបាន លុះត្រាតែមានសេចក្ដីស្នើសុំពី អ្នកតំណាងរាស្ត្រយ៉ាងតិចមួយភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ហើយត្រូវបានអនុម័តយល់ព្រមដោយសម្លេងភាគច្រើន ពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ |

## ៣. សេចក្ដីស្នើវិសោធនកម្មមាត្រា ១២០ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

| **អត្ថបទដើម** | **អត្ថបទស្នើ** |
|---|---|
| **មាត្រា ១២០ ថ្មី៖**<br>សមាជិករដ្ឋសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ទៅតាមករណីណាមួយដូចខាងក្រោម៖<br>• សាមីខ្លួនទទួលមរណភាព។<br>• សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។<br>• សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា។<br>• សាមីខ្លួន ត្រូវតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។<br>• សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។ | **មាត្រា ១២០ ថ្មី (មួយ)៖**<br>សមាជិករដ្ឋសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ទៅតាមករណីណាមួយដូចខាងក្រោម៖<br>• សាមីខ្លួនទទួលមរណភាព។<br>• សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។<br>• សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា ហើយបញ្ជាក់ពីមូលហេតុ និងផ្សព្វផ្សាយជាសាធារណៈ។<br>• សាមីខ្លួន ត្រូវតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។<br>• សាមីខ្លួនបាត់បង់សមាជិកភាព ពីគណបក្សនយោបាយរបស់ខ្លួន ដែលមានការសម្រេចជាលាយលក្ខណ៍អក្សរ តែមិនមែនមូលហេតុដោយសារការ |

| | |
|---|---|
| កាលបើសមាជិករដ្ឋសភារូបណាមួយ ត្រូវបាត់បង់សមាជិកភាពមានរយៈពេលប្រាំមួយ(០៦)ខែយ៉ាងតិចមុនចប់នីតិកាល សាមីគណបក្សនយោបាយនោះ អាចស្នើជ្រើសតាំងសមាជិកថ្មីជំនួស ដោយជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានឈ្មោះ តាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត នៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះ មកជំនួស ដោយមិនបាច់បោះឆ្នោតឡើងវិញ។ | <u>បញ្ចេញមតិខុសឆ្គង។</u><br>កាលបើសមាជិករដ្ឋសភារូបណាមួយ ត្រូវបាត់បង់សមាជិកភាពមានរយៈពេលប្រាំមួយ(០៦)ខែ យ៉ាងតិចមុនចប់នីតិកាល សាមីគណបក្សនយោបាយនោះ អាចស្នើជ្រើសតាំងសមាជិកថ្មីជំនួស ដោយជ្រើសរើសក្នុងចំណោមបេក្ខជន ដែលមានឈ្មោះតាមលំដាប់លេខរៀង ក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះ មកជំនួស ដោយមិនបាច់បោះឆ្នោតឡើងវិញ។ |